**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០២ ករណីថ្មី ជាបុរសជនជាតិឥណ្ឌូណេស៊ី និងមានវីរុសកូវីដ១៩ និងមានអ្នកជាសះស្បើយចំនួន ០១នាក់

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១៨:០០នាទី បានបង្ហាញលទ្ធផលវិភាគវត្ថុសំណាក វិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២ ករណីថ្មីទៀត និង ០១ ករណី ដែលបានចាកចេញពីកម្ពុជាដោយមិនរង់ចាំលទ្ធផលតេស្ត (មិនរាប់បញ្ចូលទៅក្នុងករណីថ្មីព្យាបាលនៅកម្ពុជា) មានដូចខាងក្រោម៖

**១. នៅរាជធានីភ្នំពេញ៖ ០១ ករណី ជាជនជាតិស៊ុយអែត**

បុរសអាយុ ៣៨ឆ្នាំ មិនមានរោគសញ្ញាបានមកសុំវិញ្ញាបនបត្របញ្ជាក់សុខភាពសម្រាប់ការធ្វើដំណើរ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានលទ្ធផល វិជ្ជមានវីរុសកូវីដ១៩។ មុនចេញលទ្ធផលពីមន្ទីរពិសោធន៍នៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បុគ្គលនេះ បានចាកចេញពីកម្ពុជាទៅប្រទេសថៃ នាយប់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ១៨:០០នាទី តាមជើងហោះហើរបាងកកអ៊ែរវ៉េ។ ក្រសួងសុខាភិបាល មិនរាប់បញ្ចូលជាករណីថ្មីព្យាបាលនៅប្រទេសកម្ពុជា។

**២. នៅខេត្តសៀមរាប៖ ០២ ករណី ជាជនជាតិឥណ្ឌូនេស៊ី**

បុរសអាយុ ៩១ឆ្នាំ និងបុរសអាយុ ៨៨ឆ្នាំ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឱ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តសៀមរាបរួចហើយ។ បុរស០២នាក់នេះ បានធ្វើតេស្តនៅមន្ទីរពេទ្យផាយ៉ាថៃ ទីក្រុងបាងកក ឃើញវិជ្ជមានវីរុសកូវីដ១៩ ដោយសារសាមីខ្លួនមិនមានថវិកាបង់ថ្លៃពេទ្យនៅទីនោះ ពួកគាត់ក៏បានធ្វើដំណើរមកព្យាបាលនៅប្រទេសកម្ពុជា ហើយក្រុមការងាររបស់មន្ទីរសុខាភិបាលខេត្តសៀមរាប បានយកវត្ថុសំណាករបស់បុគ្គលទាំងពីរនាក់ខាងលើ ទៅធ្វើវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ១៩។

ដោយឡែក ក្រុមការងាររបស់មន្ទីរសុខាភិបាលខេត្តសៀមរាប បានរកឃើញបុគ្គលចំនួន ៣៩០នាក់ ដែលជាអ្នកប៉ះពាល់ប្រយោលជាមួយអ្នកទេសចរជនជាតិបារាំងនៅខេត្តព្រះសីហនុ។ បច្ចុប្បន្ន ពួកគាត់ស្ថិតនៅក្រោមការតាមដានសុខភាពរបស់មន្ទីរសុខាភិបាលខេត្តសៀមរាប ក្នុងរយៈពេល ១៤ថ្ងៃ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០-៨៨៤ ៩០៩

**៣. នៅខេត្តកោះកុង៖ ០១ ករណី ជាជនជាតិខ្មែរ**

បុរសអាយុ ៥៧ឆ្នាំ (មានអាស័យដ្ឋាននៅខេត្តកំពត) ដែលបានសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានពីរលើក។

**៤. សរុបករណីវិជ្ជមានវីរុសកូវីដ ១៩ នៅទូទាំងប្រទេស៖**

គ្រឹមម៉ោង២០:០០ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ ១៩ សរុបទាំងអស់មានចំនួន ៩៨នាក់ (ស្រី ២៥នាក់ ប្រុស៧៣នាក់) ក្នុងនោះមានចំនួន ១១នាក់ ដែលបានជាសះស្បើយ (ដោយមិនរាប់បញ្ចូលជនជាតិស៊ុយអែត ០១នាក់ ដែលបានចាកចេញពីកម្ពុជាដោយគាត់មិននៅរង់ចាំទទួលលទ្ធផលតេស្ត)។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០

### និន្នាការនៃចំនួនវិជ្ជមានកូវីដ ១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០

ចំនួនករណីវិជ្ជមានកូវីដ ១៩ ថ្មីដែលបានរកឃើញប្រចាំថ្ងៃ

**សរុបៈ ៩៨ ករណី**




ប្រភពៈ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០

### ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

**សរុប៖ ៩៨ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃ ២៦ ខែមីនា ឆ្នាំ២០២០

### ករណីវិជ្ជមានកូវីដ ១៩ តាមភេទ
### ក្នុងចំណោម ៩៨ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ៩៨ករណី




ប្រភព៖ ក្រសួងសុខាភិបាល